ក្រសួងសុខាភិបាល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល

ក្រសួងសុខាភិបាល សូមជំរាបជូនសាធារណជនមេត្តាជ្រាបថា នៅក្នុងសភាពការណ៍បច្ចុប្បន្នដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ ប៉ុន្តែក្នុងពេលនេះកម្ពុជាមិនទាន់មានការរាតត្បាតក្នុងសហគមន៍របស់យើងទេ។ ករណីទាំងអស់សុទ្ធតែជាករណីនាំចូលពីក្រៅប្រទេស។

ក្រសួងសុខាភិបាលបានត្រៀមរៀបចំជាស្រេច នូវឧបករណ៍ សំភារៈបរិក្ខារ ធនធាន និងមធ្យោបាយ ដើម្បីឆ្លើយតបជាយថាហេតុចំពោះការរាតត្បាតនៃជំងឺនេះ នៅក្នុងប្រទេសកម្ពុជា។ កន្លងមក ក្រសួងបានរៀបចំទីកន្លែងថែទាំនិងព្យាបាលអ្នកជំងឺកូវីដ១៩ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យកុមារជាតិ មន្ទីរពេទ្យគន្ធបុប្ផាភ្នំពេញ មន្ទីរពេទ្យជ័យវរ្ម័នទី៧សៀមរាប និងនៅមន្ទីរពេទ្យខេត្តទាំង២៤។ ដោយពិនិត្យឃើញថាការកើនឡើងនៃអ្នកស្នើសុំពិនិត្យធ្វើតេស្តច្រើន ក្រសួងសុខាភិបាលបានពិភាក្សាជាមួយនឹងអាជ្ញាធររាជធានីភ្នំពេញ ពង្រីកបន្ថែមអគារថែទាំព្យាបាល ដែលមានចំណុះ ១០០គ្រែ បន្ថែមទៀត នៅអតីតមណ្ឌលសុខភាពចាក់អង្រែ ក្នុងសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

ដើម្បីសំដែងនូវសាមគ្គីភាព និងជួយគ្នាក្នុងមុខវិជ្ជាជីវៈពេទ្យក្នុងគ្រាលំបាក ក្រសួងសូមអំពាវនាវដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្ភពតេជោចូលរួមក្នុងភារកិច្ចដ៏ឧត្តុង្គឧត្តមដើម្បីប្រយុទ្ធនឹងវីរុសកូវីដ១៩នេះ។ ក្រសួងសុខាភិបាលសូមសំដែងនូវការអរគុណទុកជាមុនដល់ការចូលរួម ដោយស្មារតីមនុស្សធម៌ និងវិជ្ជាជីវៈពេទ្យ ជាមួយមន្ត្រី បុគ្គលិកសុខាភិបាលរបស់យើងដែលកំពុងសកម្មប្រយុទ្ធនឹងការរាតត្បាតនេះ។ លោកគ្រូ អ្នកគ្រូពេទ្យស្ម័គ្រចិត្តដែលមានគោលបំណងចូលរួមក្នុងសកម្មភាពនេះ សូមមេត្តាមកចុះឈ្មោះនៅក្រសួងសុខាភិបាល ជាន់ផ្ទាល់ដីដែលមានអាសយដ្ឋាននៅ ដីឡូតិ៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) រាជធានីភ្នំពេញ រឺ តាមប្រព័ន្ធទំនាក់ទំនង Telegram របស់លោក ហ៊ុយ ឆេងតាកក៏ក្រ ០៧៦ ៨៨៨ ៩១១៨។

ក្រោយពីបានចុះឈ្មោះ លោកគ្រូពេទ្យ អ្នកគ្រូពេទ្យស្ម័គ្រចិត្ត នឹងទទួលការបណ្តុះបណ្តាលបន្ថែម នៅវិទ្យាស្ថានជាតិសុខភាពសាធារណៈ ដែលមានទីតាំងនៅក្នុងបរិវេណក្រសួងសុខាភិបាល។

ថ្នាក់ដឹកនាំ បុគ្គលិក និងមន្ត្រីសុខាភិបាលទាំងអស់ប្តេជ្ញាខិតខំប្រឹងប្រែងបំពេញភារកិច្ច ប្រយុទ្ធនឹងការរាតត្បាតជំងឺនេះ និងថែទាំសុខភាពប្រជាពលរដ្ឋប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ និងទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល។

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**